KIDS GOD WORSHIP

www.kidworship.kr

# ចំណងជើង៖ អាហារថ្ងៃចុងក្រោយ



129Page

**Narration** ពិធីបុណ្យនំប៉័ងឥតមេដែលគេហៅថា បុណ្យចម្លងនោះត្រូវបានខិតជិតមកដល់។
ពិធីបុណ្យចម្លងគឺជាពិធីមួយដែលរំលឹកដល់ការរំដោះរាស្ត្រអ៊ីស្រាអែលពីភាពជាទាសករនៅស្រុកអេស៊ីប ដើម្បីអោយពួកគេមាននូវសេរីភាពរបស់ពួកគេជាប្រជាជាតិមួយ។
ចំពោះរាស្ត្រអ៊ីស្រាអែលការប្រារព្ធពិធីបុណ្យចម្លង
គឺជាថ្ងៃមួយដែលពួកគេមានអំណរសប្បាយរីករាយខ្លាំងណាស់។
ព្រះយេស៊ូទ្រង់បានជ្រាបថាពេលវេលារបស់ទ្រង់នៅលើផែនដីត្រូវបានមកដល់
ហើយទ្រង់នឹងត្រលប់ទៅឋានបរមសុខ វិញ។
ដូច្នេះហើយមុនពេលថ្ងៃនៃពិធីបុណ្យចម្លងបានមកដល់
ព្រះយេស៊ូបានហៅសិស្សរបស់ទ្រង់ទាំងអស់មកបរិភោគអាហារនៅថ្ងៃចុងក្រោយរួមគ្នា។

---



130Page

**Narration** នៅពេលដែលពួកសិស្សបានមកដល់ពួកគេបានអង្គុយនៅឯតុ។
ព្រះយេស៊ូចាប់ផ្តើមលាងជើងអោយពួកសិស្ស។ ពួកគេមានភាពងឿងឆ្ងល់ជាខ្លាំង។

**ពួកសិស្ស** ព្រះយេស៊ូ! តើឲ្យទ្រង់លាងជើងឲ្យពួកទូលបង្គំយ៉ាងម៉េចទៅ? វាពិតជាមិនត្រឹមត្រូវទេ!

**Narration** ទោះបីជាពួកសិស្សមានការស្ទាក់ស្ទើរចំពោះរឿងនេះក៏ដោយ
ក៏ព្រះយេស៊ូបានលាងជើងរបស់ពួកសិស្សម្នាក់ម្តងៗ
ដ្បិតពួកគេមិនដឹងថាពួកគេត្រូវធ្វើអ្វីនោះឡើយ។ ចុងក្រោយបានដល់វេនរបស់ពេត្រុស។

**ពេត្រុស** “ព្រះអង្គអើយហេតុអ្វីបានជាព្រះអង្គលាងជើងដ៏កខ្វក់របស់ទូលបង្គំ? ទេ មិនសមទេ
គឺមិនត្រូវអោយទ្រង់លាងជើងរបស់ទូលបង្គំឡើយ”។

**ព្រះយេស៊ូ** “ប្រសិនបើខ្ញុំមិនលាងជើងអ្នកទេ នោះអ្នកមិនអាចរួមជាមួយខ្ញុំតទៅទៀតបានឡើយ”។

**ពេត្រុស** “ព្រះជាម្ចាស់អើយ បើដូច្នោះសូមកុំលាងតែជើងប៉ុណ្ណោះ សូមលាងទាំងដៃ
ទាំងក្បាលផង”។

**Narration** បន្ទាប់មកពេត្រុសបានផ្លាស់ប្រែចិត្តរបស់គាត់
ហើយអោយព្រះយេស៊ូបានលាងអោយគាត់បន្ថែមទៀត។

---



131Page

**Narration** កាលព្រះយេស៊ូបានលាងជើងអោយពួកសិស្សរួចហើយ ព្រះអង្គយាងមកតុ
ទាំងមានព្រះបន្ទូលទៅពួកគេថា៖

**ព្រះយេស៊ូ** ឥឡូវនេះ! បើខ្ញុំជាព្រះអម្ចាស់ និងជាព្រះគ្រូបានលាងជើងអោយអ្នករាល់គ្នាទៅហើយ
អ្នករាល់គ្នាក៏ត្រូវលាងជើង អោយគ្នាទៅវិញទៅមកដែរ។
ខ្ញុំបានធ្វើជាគំរូអោយអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នាដែរ។

**Narration** ពួកសិស្សបានរក្សាទុកនូវព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងចិត្តរបស់ពួកគេ។
បន្ទាប់មកព្រះយេស៊ូយកនំប៉័ងមកកាច់ អរព្រះគុណព្រះជាម្ចាស់
ហើយប្រទានអោយពួកសិស្សដោយមានព្រះបន្ទូលថា៖.



132Page

| | |
|---|---|
| ព្រះយេស៊ូ | “នេះជារូបកាយខ្ញុំ សុំយកពិសារចុះ” សូមធ្វើបែបនេះដើម្បីរំលឹកពីខ្ញុំ។ |
| Narration | បន្ទាប់មកព្រះអង្គយកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានអោយពួកសិស្ស<br>ទាំងមានព្រះបន្ទូលថា៖ |
| ព្រះយេស៊ូ | សុំយកពិសារទាំងអស់គ្នាចុះ នេះជាលោហិតរបស់ខ្ញុំ<br>គឺជាលោហិតនៃសម្ព័ន្ធមេត្រីថ្មីដែលត្រូវបង្ហូរ<br>ដើម្បីលើកលែងទោសមនុស្សទាំងអស់អោយរួចពីបាប” សូមធ្វើការនេះ<br>ដើម្បីរំលឹកពីខ្ញុំចុះ។ |

.................................................................................................



133Page

| | |
|---|---|
| Narration | បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖ |
| ព្រះយេស៊ូ | “ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា<br>មានម្នាក់នឹងនាំគេមកចាប់ខ្ញុំ”។ |
| Narration | ព្រះយេស៊ូកំពុងតែមានព្រះបន្ទូល ពីយូដាសអ៊ីស្ការីយ៉ុត។<br>ពេលនោះពួកសិស្សមានភាពងឿងឆ្ងល់យ៉ាងខ្លាំង រួចព្រះយេស៊ូមានព្រះបន្ទូលបន្តទៀតថា៖ |
| ព្រះយេស៊ូ | “បុត្រមនុស្សត្រូវតែស្លាប់ ដ្បិតជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់<br>ប៉ុន្តែអ្នកដែលនាំគេមកចាប់បុត្រមនុស្ស នឹងត្រូវវិនាសជាមិនខាន។ ចំពោះអ្នកនោះ<br>បើមិនបានកើតមកទេ ទើបប្រសើរជាង”។ |
| Narration | ពួកសិស្សព្រួយចិត្តក្រៃលែង ម្នាក់ៗទូលសួរព្រះយេស៊ូថា៖ |
| ពួកសិស្ស | “បពិត្រព្រះអម្ចាស់! តើទូលបង្គំឬ”? |
| ព្រះយេស៊ូ | “អ្នកណាជ្រលក់នំប៉័ងក្នុងចានជាមួយខ្ញុំ គឺអ្នកនោះហើយដែលនាំគេមកចាប់ខ្ញុំ”។ |



134Page

| | |
|---|---|
| Narration | បន្ទាប់ពីព្រះយេស៊ូបានអោយអាហារទៅយូដាសអ៊ីស្ការីយ៉ុត រួចទ្រង់មានព្រះបន្ទូលថា៖ |
| ព្រះយេស៊ូ | អ្វីដែលអ្នកត្រូវធ្វើ សុំប្រញាប់ធ្វើវាចុះ! |
| Narration | បន្ទាំពីព្រះយេស៊ូមានព្រះបន្ទូលរួចភ្លាម យូដាសបានក្រោកចេញពីតុអាហារយ៉ាងប្រញ៉ាប់។<br>ដ្បិតពួកសិស្សផ្សេងទៀតពួកគេមិនបានដឹងពីផែនការរបស់យូដាសបានរៀបចំធ្វើនោះឡើយ។ |

.................................................................................................

| | |
|---|---|
| Narration | បន្ទាប់ពីបរិភោគអាហារពេលល្ងាចរួច ព្រះយេស៊ូបានមានព្រះបន្ទូលទៅពួកសិស្សថា៖ |
| ព្រះយេស៊ូ | ទោះបីជាអ្នកទាំងអស់គ្នាបានដើរតាមខ្ញុំរហូតដល់ឥឡូវនេះក៏ដោយ<br>ប៉ុន្តែនៅពេលបន្តិចទៀតនោះ អ្នកទាំងអស់គ្នានឹងក្បត់ខ្ញុំ ហើយបោះបង់ចោលខ្ញុំ។ |
| ពេត្រុស | “បពិត្រព្រះអម្ចាស់! ទោះបីអ្នកឯទៀតបោះបង់ចោលព្រះអង្គទាំងអស់គ្នាក៏ដោយ<br>ក៏ទូលបង្គំមិនសុខចិត្តបោះបង់ចោលព្រះអង្គជាដាច់ខាត”។ |
| Narration | ក្នុងចំណោមសិស្សទាំងដប់ពីរនាក់ ព្រះយេស៊ូស្រឡាញ់ពេត្រុសជាងគេ។ |
| ព្រះយេស៊ូ | “ពេត្រុស! ខ្ញុំសុំប្រាប់អ្នកអោយដឹងច្បាស់ថា នៅយប់នេះ មុនមាន់រងាវ<br>អ្នកនឹងបដិសេធបីដងថាមិនស្គាល់ខ្ញុំ”។ |
| Narration | លោកពេត្រុសបានទូលព្រះអង្គថា៖ |
| ពេត្រុស | “ទោះបីជាទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏ទូលបង្គំមិនបដិសេធថា<br>មិនស្គាល់ព្រះអង្គជាដាច់ខាត”។ |

**Narration** ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសិស្សថា៖

**ព្រះយេស៊ូ** ខ្ញុំនឹងត្រូវទៅកន្លែងមួយផ្សេងទៀត
តែអ្នកទាំងអស់គ្នាមិនអាចទៅជាមួយខ្ញុំបានឡើយពេលនេះ។
ប៉ុន្តែអ្នកទាំងអស់គ្នានឹងអាចទៅទីនោះនៅពេលក្រោយ។
ខ្ញុំនឹងទៅស្ថានបរមសុខដើម្បីរៀបចំកន្លែងសំរាប់អ្នករាល់គ្នា
ពេលខ្ញុំរៀបចំកន្លែងទុកសំរាប់អ្នករាល់គ្នារួចហើយ ខ្ញុំនឹងត្រឡប់មកវិញ
យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីអោយអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។
ព្រះយេស៊ូបានសន្យាថាទ្រង់នឹងត្រឡប់មកបរិភោគអាហារចុងក្រោយជាមួយពួកគេម្តងទៀត។

.................................................................................................



135Page

**Narration** រហូតមកដល់ថ្ងៃនេះសិស្សរបស់ព្រះយេស៊ូតែងតែចែកនំប៉័ងនិងស្រាទំពាំងបាយជូ
ជាការរំលឹងដល់ការបរិភោគអាហារចុងក្រោយ។
សព្វថ្ងៃនេះសិស្សរបស់ព្រះយេស៊ូសុទ្ធតែបានដឹងនិងធ្វើ “ពិធីអរព្រះគុណ”
សំរាប់អរព្រះគុណទៅកាន់ទ្រង់។
ហើយពួកយើងតែងតែចងចាំពីការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាងជំនួសបាបរបស់ពួ
កយើង។ វាពិតជាឆ្លុះបញ្ចាំងពីការដែលពួកយើងចង់អរព្រះគុណទៅកាន់ទ្រង់។